**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងខេត្តព្រះសីហនុ

**សំណុំរឿងព្រហ្មទណ្ឌ**
លេខៈ ៥៦១ ចុះថ្ងៃទី២៤
ខែ ឧសភា ឆ្នាំ ២០១៩

**សំណុំរឿងជំនុំជម្រះ**
លេខ៤០១ ចុះថ្ងៃទី០១
ខែ មេសា ឆ្នាំ ២០២១

**សាលក្រម**
លេខៈ ៦៤០ / ៥៦ (ញ)
ចុះថ្ងៃទី០១.០៩ ២០២២

# ក្នុងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តព្រះសីហនុ

បានបើកសវនាការជាសាធារណៈនៅសាលសវនាការនៃសាលាដំបូងខេត្តព្រះសីហនុ នាថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២ ដោយមានសមាសភាពជំនុំជម្រះដូចខាងក្រោម៖

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] ចៅក្រមនៃសាលាដំបូងខេត្តព្រះសីហនុ

**តំណាងអយ្យការ**

-លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តព្រះសីហនុ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៥៦១ ចុះថ្ងៃទី២៤.០៥.២០១៩ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] វ៉េន ភេទប្រុស កើតឆ្នាំ១៩៦២ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅឃុំអង្គរមាស ស្រុកដងទង់ ខេត្តកំពត កម្រិតវប្បធម៌មិនចេះអក្សរ មុខរបរនៅផ្ទះ។អាសយដ្ឋាននៅភូមិចំណោតរាម ឃុំ [redacted] ខេត្តព្រះសីហនុ។ប្រពន្ធឈ្មោះហាវ រ៉ន មានកូន០៧នាក់។ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស)។ទោសពីមុនគ្មាន។

២-ឈ្មោះ [redacted] រ៉ន ភេទស្រី អាយុ ៥៨ឆ្នាំ ជនជាតិខ្មែរ អាសយដ្ឋាននៅ [redacted] ត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។ប្តីឈ្មោះ [redacted]។

៣-ឈ្មោះ [redacted] សារី ភេទប្រុស កើតឆ្នាំ១៩៧៩ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ១ សង្កាត់លេខ៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ។អាសយដ្ឋាននៅ [redacted] ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

៤-ឈ្មោះ [redacted] ពៅ ភេទស្រី អាយុ៤០ឆ្នាំ ជនជាតិខ្មែរ អាសយដ្ឋាននៅភូមិ [redacted] ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

៥-ឈ្មោះ [redacted] សាន់ ភេទប្រុស កើតឆ្នាំ១៩៥៩ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិពូទៀង ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កម្រិតវប្បធម៌ថ្នាក់ទី៧ មុខរបរនៅផ្ទះ។អាសយដ្ឋាននៅភូមិ [redacted] ខេត្តព្រះសីហនុ។ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន០៨នាក់។ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (ស) ទោសពីមុនគ្មាន។

៦-ឈ្មោះ [redacted] មិន ភេទស្រី អាយុ ៥៥ឆ្នាំ ជនជាតិខ្មែរ អាសយដ្ឋាន [redacted] ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

៧-ឈ្មោះ [redacted] រឿត ភេទប្រុស អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ អាសយ [redacted]



Scanned with CamScanner

ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

៨-ឈ្មោះ [redacted] ចាន់ដារ៉ា ភេទស្រី អាយុ២៨ឆ្នាំ ជនជាតិខ្មែរ អាសយដ្ឋាន [redacted] ក្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

ជាប់ចោទពីបទរំលោភ ប្រព្រឹត្តនៅភូមិពូធឿង ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែមករា ,ខែកុម្ភៈ រហូតដល់អំឡុងខែសីហា ឆ្នាំ២០១៨។បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

-មេធាវី [redacted] ពៅ ការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] សាន់ មានការិយាល័យនៅក្រុមមេធាវីយុត្តិធម៌និងសហការី [redacted] ភូមិព្រែកតាគង់ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] គុប ភេទប្រុស អាយុ៥៥ឆ្នាំ និងឈ្មោះ [redacted] សុភី ភេទស្រី អាយុ៣៩ឆ្នាំ ជនជាតិខ្មែរ (ប្តីប្រពន្ធ) មានអាសយដ្ឋាននៅ [redacted] ភូមិដំណាក់ធំ២ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

-មេធាវី [redacted] សារិទ្ធ ការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] គុប និងឈ្មោះ [redacted] សុភី មានការិយាល័យ [redacted] សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ។

-បានឃើញ ពាក្យបណ្តឹង ចុះថ្ងៃទី១៦.០៥.២០១៩ របស់ឈ្មោះ [redacted] គុប និងឈ្មោះ [redacted] សុភី។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ៥៩១៧ អ.យ.ខ/១៩ ចុះថ្ងៃទី៣០.១០.២០១៩ របស់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ១៦៥ អ.យ.ក/២១ ចុះថ្ងៃទី២២.០២.២០២១ របស់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ។

-បានឃើញ ដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះលេខ:១៨៦៧ គណ/២១ ចុះថ្ងៃទី១៧.០៣.២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តព្រះសីហនុ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ:៩៨២/៨២ (ញ) ចុះថ្ងៃទី២៨.១២.២០២១ របស់សាលាដំបូងខេត្តព្រះសីហនុ ដែលមានខ្លឹមសារនៃសេចក្តីសម្រេច៖

១-ផ្តន្ទាទោសលើ៖

ក.ឈ្មោះ [redacted] វេន,ឈ្មោះ [redacted] សារី,ឈ្មោះ [redacted] សាន់ និងឈ្មោះ [redacted] រឿន (សាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់០២(ពីរ)ឆ្នាំ និងពិន័យជាប្រាក់ក្នុងម្នាក់ៗចំនួន៤,០០០,០០០(បួនលាន)រៀល។

ខ.ឈ្មោះ [redacted] វែន,ឈ្មោះ [redacted] ពៅ,ឈ្មោះ [redacted] មិន និងឈ្មោះ [redacted] ចាន់ដារ៉ា (សាវតារជាតិដូចខាងលើ) ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់០៨ (ប្រាំបី)ខែ។

ពីបទរំលោភ ប្រព្រឹត្តនៅភូមិពូធឿង ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែមករា ,ខែកុម្ភៈ រហូតដល់អំឡុងខែសីហា ឆ្នាំ២០១៨។បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឲ្យចាប់ខ្លួន និងឃុំខ្លួនលើឈ្មោះ [redacted] វេន,ឈ្មោះ [redacted] សារី,ឈ្មោះ [redacted] សាន់,ឈ្មោះ [redacted] មិន និងឈ្មោះ [redacted] រឿន (មានសាវតារជាតិដូចខាងលើ) នៅពន្ធនាគារខេត្តព្រះសីហនុ មុនអនុវត្តទោសតាមអំណាចសាលក្រមព្រហ្មទណ្ឌនេះ តាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។



Scanned with CamScanner

៣-បង្គាប់ឲ្យឈ្មោះ៖

ក-ឈ្មោះ [redacted] វ៉ន និងឈ្មោះ [redacted]វ៉ន (ប្ដីប្រពន្ធ) សងសំណងថ្លៃទិញដីចំនួន២៤.០០០(ពីរម៉ឺនបួនពាន់)ដុល្លារអាមេរិក និងសំណងជម្ងឺចិត្តចំនួន១៦.០០០.០០០(ដប់ប្រាំមួយលាន)រៀល។

ខ-ឈ្មោះ [redacted] រឿន និងឈ្មោះ [redacted]ន់ជាក់ (ប្ដីប្រពន្ធ) សងសំណងថ្លៃទិញដីចំនួន១៣.៨០០(មួយម៉ឺនបីពាន់ប្រាំបីរយ)ដុល្លារអាមេរិក និងសំណងជម្ងឺចិត្តចំនួន១៦.០០០.០០០(ដប់ប្រាំមួយលាន)រៀល។

គ-ឈ្មោះ [redacted] សារ៉ី និងឈ្មោះ [redacted]ពៅ (ប្ដីប្រពន្ធ)សងសំណងថ្លៃទិញដីចំនួន១០.០០០(មួយម៉ឺន)ដុល្លារអាមេរិក និងសំណងជម្ងឺចិត្តចំនួន១៦.០០០.០០០(ដប់ប្រាំមួយលាន)រៀល។

ឃ-ឈ្មោះ [redacted] សាន់ និងឈ្មោះ [redacted] ម៉ិន (ប្ដីប្រពន្ធ) សងសំណងថ្លៃទិញដីចំនួន១២.០០០(មួយម៉ឺនពីរពាន់)ដុល្លារអាមេរិក និងសំណងជម្ងឺចិត្តចំនួន១៦.០០០.០០០(ដប់ប្រាំមួយលាន)រៀល ទៅឲ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះអេង គុប និងឈ្មោះនឹង សុភី (ប្ដីប្រពន្ធ)។

-សាលក្រមនេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ កំបាំងមុខចុងចម្លើយទាំង និងប្រកាសជាសាធារណៈនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ ចុងចម្លើយមានសិទ្ធិប្ដឹងទាស់ និងបើកផ្លូវប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញ កំណត់ហេតុជូនដំណឹងស្ដីពីសាលក្រមកំបាំងមុខ ចុះថ្ងៃទី១៤.០៧.២០២២ របស់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ និងសម្រង់សេចក្ដីសុំប្ដឹងទាស់ ចុះថ្ងៃទី១៤.០៧.២០២២ របស់សាលាដំបូងខេត្តព្រះសីហនុ។

## អង្គហេតុនៃរឿងមានដូចតទៅ

-នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨ ឈ្មោះនឹង សុភី និងប្ដីឈ្មោះអេង គុប បានទិញដីពីឈ្មោះរុត រឿន និងប្រពន្ធឈ្មោះតែ ចាន់ដាក់ ទំហំ៣១ម៉ែត្រ គុណនឹង២០ម៉ែត្រ ក្នុងតម្លៃ១៣.៨០០ដុល្លារអាមេរិក ដោយបានប្រគល់លុយរួចហើយ។នៅថ្ងៃទី១៧.០១.២០១៨ បានទិញដីពីឈ្មោះលុយ វ៉ន និងប្រពន្ធឈ្មោះហាវ វ៉ន ទំហំ២៦ម៉ែត្រ គុណនឹង៣១ម៉ែត្រ ក្នុងតម្លៃ២៤.០០០ដុល្លារអាមេរិក បានប្រគល់លុយរួចហើយ។នៅថ្ងៃទី០៧.០២.២០១៨ បានទិញដីពីឈ្មោះតាយ សារ៉ី និងប្រពន្ធឈ្មោះសុំ ពៅ ទំហំ២១ម៉ែត្រ គុណនឹង៣០ម៉ែត្រ ក្នុងតម្លៃ១០.០០០ដុល្លារអាមេរិក បានប្រគល់លុយរួចហើយ។នៅថ្ងៃទី០៤.០៨.២០១៨ បានទិញដីពីឈ្មោះមុង សាន និងប្រពន្ធឈ្មោះសយ ម៉ិន ទំហំ២៨ម៉ែត្រ គុណនឹង២០ម៉ែត្រ ក្នុងតម្លៃ១២.០០០ដុល្លារអាមេរិក បានប្រគល់លុយរួចហើយ។ដីដែលឈ្មោះនឹង សុភី និងឈ្មោះអេង គុប ទិញពីក្រុមគ្រួសារទាំងបួននោះមានទីតាំងស្ថិតនៅភូមិអូរឿង ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។ក្រោយពីទិញបានហើយឈ្មោះនឹង សុភី និងឈ្មោះអេង គុប បានជួលគេឲ្យធ្វើរបងព័ទ្ធជុំវិញដី ស្រាប់តែមានគេមកជំទាស់ថាដីដែលខ្លួនទិញនេះជាដីរបស់គេដែលមានប័ណ្ណកម្មសិទ្ធិរួចហើយ ឈ្មោះនឹង សុភី និងឈ្មោះអេង គុប ក៏បានធ្វើការស្រាវជ្រាវទើបឃើញថាដីដែលខ្លួនទិញពីក្រុមគ្រួសារទាំងបួនខាងលើពិតជាដីរបស់គេ ហើយគេមានប័ណ្ណកម្មសិទ្ធិរួចហើយប្រាកដមែន។ឈ្មោះនឹង សុភី និងឈ្មោះអេង គុប បានហៅក្រុមគ្រួសារទាំងបួនដែលបានលក់ដីឲ្យនោះមកដោះស្រាយតែពួកគេបានគេចវេសមិនព្រមដោះស្រាយឡើយ ទើបដាក់ពាក្យបណ្ដឹងមកអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ ដើម្បីចាត់ការតាមផ្លូវច្បាប់។

**ចៅក្រមស៊ើបសួរ**

-ជនជាប់ចោទឈ្មោះ[redacted] វ៉េន បានឆ្លើយថាៈខ្លួននិងប្រពន្ធខ្លួនឈ្មោះ[redacted] ពិតជាបានលក់ដីទំហំ៣០ម៉ែត្រ គុណនឹង២០ម៉ែត្រ មានទីតាំងស្ថិតនៅភូមិព្រៃធៀង ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ក្នុងតម្លៃ២៥.០០០(ពីរម៉ឺនប្រាំពាន់)ដុល្លារអាមេរិក ទៅឲ្យឈ្មោះ[redacted] គុប និងប្រពន្ធឈ្មោះ[redacted] សុភី ហើយភាគីអ្នកទិញបានប្រគល់ប្រាក់មកឲ្យខ្លួនគ្រប់ចំនួនហើយ ប៉ុន្តែប្រាក់ថ្លៃដីនេះអ្នកវត់ការយកអស់១០,០០០(មួយម៉ឺន)ដុល្លារអាមេរិក ហើយខ្លួនបានតែ១៥,០០០(មួយម៉ឺនប្រាំពាន់)ដុល្លារអាមេរិក ប៉ុណ្ណោះ។ ក្រោយពីខ្លួនលក់ដីរួចហើយ ខ្លួនបានដឹងថាឈ្មោះ[redacted] គុប និងឈ្មោះ[redacted]សុភី បានទៅធ្វើរបងនៅលើដីនោះ ត្រូវបានភាគីមួយទៀតមកជំទាស់ថាជាដីរបស់គេ។កន្លងមកឈ្មោះ[redacted]គុប និងឈ្មោះ[redacted] សុភី បានមមកទំនាក់ទំនងខ្លួនឲ្យសងប្រាក់ទៅគាត់វិញដែរ ប៉ុន្តែខ្លួនមិនមានប្រាក់សងដោយសារចាយវាយអស់ហើយ។នៅក្នុងរឿងនេះខ្ញុំបាទសំណូមពរសូមឲ្យតុលាការមេត្តាអនុគ្រោះទោសដល់រូបខ្លួនដោយសារតែរូបខ្លួនសព្វថ្ងៃកំពុងមានជម្ងឺសួតបើមិនព្យាបាលទាន់ពេលវេលាទេរូបខ្លួនអាចស្លាប់នៅក្នុងពន្ធនាគារ។

-ជនជាប់ចោទឈ្មោះ[redacted] សាន់ បានឆ្លើយថាៈខ្លួននិងប្រពន្ធខ្លួនឈ្មោះ[redacted] ពិតជាបានលក់ដីទំហំ២៨ម៉ែត្រ គុណនឹង២០ម៉ែត្រ មានទីតាំងស្ថិតនៅភូមិព្រៃធៀង ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ក្នុងតម្លៃ១២.០០០(មួយម៉ឺនពីរពាន់)ដុល្លារអាមេរិក ទៅឲ្យឈ្មោះ[redacted] គុប និងប្រពន្ធឈ្មោះ[redacted]ុភី ហើយភាគីអ្នកទិញបានប្រគល់ប្រាក់មកឲ្យខ្លួនគ្រប់ចំនួនហើយ។នៅក្នុងរឿងនេះខ្ញុំទទួលស្គាល់នូវកំហុសរបស់ខ្ញុំ ហើយខ្ញុំនិងដើមបណ្តឹងរដ្ឋប្បវេណីបាននិយាយត្រូវរ៉ូវគ្នាអស់ហើយ ដោយរូបខ្ញុំសុខចិត្តសងសំណងទៅដើមបណ្តឹងនៅពេលនេះចំនួន៣,០០០(បីពាន់)ដុល្លារអាមេរិក ឯប្រាក់ដែលនៅសល់ចំនួន៩,០០០(ប្រាំបួនពាន់)ដុល្លារអាមេរិក និងប្រាក់សំណងចំនួន១៦,០០០,០០០(ដប់ប្រាំមួយលាន)រៀលខ្លួនយល់ព្រមសងទៅដើមបណ្តឹង៦ខែក្រោយទៀត។នៅក្នុងរឿងនេះខ្លួនសំណូមពរសូមតុលាការមេត្តាអនុគ្រោះទោសដល់រូបខ្លួនព្រោះថាខ្លួនមានវ័យកាន់តែចាស់ហើយអាយុ៦៣ឆ្នាំ ហើយបច្ចុប្បន្នខ្លួនក៏មានជម្ងឺប្រចាំកាយដែរ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]គុប បានឆ្លើយថាខ្លួននិងប្រពន្ធឈ្មោះ[redacted] សុភី ពិតជាបានព្រមព្រៀងជាមួយលោក[redacted] សាន់ ដូចឈ្មោះ[redacted] សាន់ ឆ្លើយជូនតុលាការនាពេលនេះប្រាកដមែន។ចំណែកឈ្មោះ[redacted]វ៉េន គាត់មិនព្រមសងប្រាក់មកខ្លួនអ្វីសោះឡើយ ខ្លួនសំណូមពរសុំឲ្យតុលាការផ្តន្ទាទោសលើឈ្មោះ[redacted] វ៉េន ឲ្យបានធ្ងន់ធ្ងរនិងយល់ព្រមតាមសម្រេចសេចក្តីនៃសាលក្រមលើកមុន។ ចំណែកឈ្មោះ[redacted]សាន់ សុំឲ្យតុលាការជួយបន្ធូរបន្ថយទោសដល់រូបគាត់ផង។

-ក្រឡាបញ្ជីបានអានកំណត់ហេតុសុខភាព ចុះថ្ងៃទី១២.០៨.២០២២ របស់សាលាខេត្តព្រះសីហនុ ពន្ធនាគារខេត្តព្រះសីហនុ ការិយាល័យអប់រំកែប្រែផ្នែកសុខាភិបាលនូវសេចក្តីទាំងស្រុងថាៈឈ្មោះ[redacted] វ៉េន ភេទប្រុស កើតឆ្នាំ១៩៦២ ជនជាតិខ្មែរ ថ្ងៃ.ខែ.ឆ្នាំឃុំខ្លួន១២.៧.២០២២ ពីបទៈឆបោក។

បានបញ្ជាក់ថាលក្ខណៈទូរទៅបច្ចុប្បន្នមានជំងឺហឺតរ៉ាំរ៉ៃ និងរលាកសួត ប្រព័ន្ធដង្ហើម២៨ដង/នាទី ប្រព័ន្ធបេះដូង ១០២/នាទី TA ១៤៣ លើ៩៦ មីលីម៉ែត្របារត ប្រព័ន្ធរំលាយអាហារចុកឆ្អល់ចុងដង្ហើម ប្រព័ន្ធតំរងនោម និងប្រដាប់បន្តពូជ ធម្មតា ប្រព័ន្ធសរសៃប្រសាទ ធម្មតា ត្រចៀក ច្រមុះ បំពង់ក ភ្នែក ធម្មតា សរុបជាលទ្ធផលនៃការពិនិត្យ បច្ចុប្បន្នៈមានជំងឺហឺតរ៉ាំរ៉ៃ និងរលាកសួត រោគវិនិច្ឆ័យChronic Astha Pneumora។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថាៈ ឆ្លងតាមការសួរដេញដោយនាពេលសវនាការនិង



Scanned with CamScanner

ពិនិត្យឯកសារនៅក្នុងសំណុំរឿង មិនមានអង្គហេតុប្លែកដែលគួរឲ្យតំណាងអយ្យការធ្វើការកត់សម្គាល់អ្វីឡើយ ហេតុដូច្នេះក្នុងនាមជាតំណាងអយ្យការ សុំតម្កល់សេចក្តីសន្និដ្ឋានប្តឹងសុំដូចសេចក្តីសន្និដ្ឋានសវនាការលើកមុននៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ដដែល និងសំណូមពរសុំឲ្យតុលាការតម្កល់ការផ្តន្ទាទោសតាមសាលក្រមលេខៈ៩៨២/៨២ (ញ) ចុះថ្ងៃទី២៨.១២.២០២១ ដដែល។

-មេធាវី[redacted] ពៅ ការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ[redacted] សាន់ បានធ្វើសេចក្តីសន្និដ្ឋានការពារថាៈកូនក្តីរបស់ខ្លួនបានទទួលស្គាល់នូវអំពើដែលបានប្រព្រឹត្តអស់ហើយ ដូចនេះខ្លួនសំណូមពរសុំឲ្យតុលាការពិចារណាអំពីស្ថានសម្រាលដល់កូនក្តីរបស់ខ្លួន៖ទី១-កូនក្តីរបស់ខ្លួនទទួលស្គាល់កំហុស។ទី២-កូនក្តីរបស់ខ្លួនយល់ព្រមសងព្យសនកម្មទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណី ហើយដើមបណ្តឹងរដ្ឋប្បវេណីនិងកូនក្តីខ្លួនបានឯកភាពគ្នាដូចដែលបានលើកឡើងក្នុងពេលសវនាការនេះ។ ទី៣-កូនក្តីរបស់ខ្លួនមានវ័យកាន់តែចាស់មកដល់ពេលនេះមានអាយុ៦៣ឆ្នាំជាងហើយនិងជាមនុស្សស្លូតបូត សុភាពរាបសារ ជាក់ស្តែងក្នុងពេលសវនាការតុលាការអាចពិនិត្យចរិកលក្ខណៈរបស់កូនក្តីខ្លួនបាន។ទី៤-កូនក្តីខ្លួនពុំធ្លាប់ត្រូវបានតុលាការផ្តន្ទាទោសពីបទល្មើសអ្វីឡើយហើយក៏មិនដែលបង្កការលំបាកដល់សមត្ថកិច្ចម្តងណាដែរ។ សេចក្តីដូចខ្លួនបានជម្រាបជូនតុលាការអំពីស្ថានសម្រាលដល់កូនក្តីខ្លួននេះខ្លួនសុំសំណូមពរដល់តុលាការមេត្តាពិចារណាអំពីស្ថានសម្រាលនេះដក់កូនក្តីរបស់ខ្លួនតាមការគួរផង។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ[redacted] វេន និងឈ្មោះ[redacted] សាន់។

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពារមេធាវីជនជាប់ចោទ។

-ក្រោយពីបានពិនិត្យឯកសារ និងភស្តុតាងនានាក្នុងសំណុំរឿង។

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

**សាលាដំបូងខេត្តព្រះសីហនុ**

**យល់ឃើញថា**

-តុលាការអាចលើកយកសំណុំរឿងព្រហ្មទណ្ឌខាងលើមកជំនុំជម្រះបាន តាមកំណត់ហេតុជូនដំណឹងស្តីពីសាលក្រមព្រហ្មទណ្ឌលេខៈ៩៨២ / ៨២(ញ) ចុះថ្ងៃទី២៨.១២.២០២១ ចុះថ្ងៃទី១៤.០៧.២០២២ ដល់ជនជាប់ចោទឈ្មោះ[redacted]វេន និងឈ្មោះហុង សាន់ របស់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ ហើយត្រូវបានជនជាប់ចោទឈ្មោះ[redacted] វេន និងឈ្មោះ[redacted]សាន់ ប្តឹងទាស់តាមសម្រង់សេចក្តីសុំប្តឹងទាស់ ចុះថ្ងៃទី១៤.០៧.២០២២ ដោយផ្អែកតាមមាត្រា៣៧១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ដូច្នេះតុលាការគប្បីពិចារណាទៅលើជនជាប់ចោទឈ្មោះ[redacted]វេន និងឈ្មោះ[redacted]សាន់ តែប៉ុណ្ណោះ។

-តាមសាលក្រមព្រហ្មទណ្ឌលេខៈ៩៨២/៨២ (ញ) ចុះថ្ងៃទី២៨.១២.២០២១ របស់សាលាដំបូងខេត្តព្រះសីហនុ ធ្វើឡើងត្រឹមត្រូវតាមច្បាប់ ហើយក្នុងពេលសវនាការពុំមានអង្គហេតុផ្ទុយនឹងអង្គហេតុនៃសាលក្រមព្រហ្មទណ្ឌលេខៈ៩៨២/៨២(ញ) ចុះថ្ងៃទី២៨.១២.២០២១ នេះឡើយ ដូច្នេះគប្បីតម្កល់អង្គហេតុដែលមាននៅក្នុងសាលក្រមព្រហ្មទណ្ឌលេខៈ៩៨២/៨២(ញ) ចុះថ្ងៃទី២៨.១២.២០២១ ទុកជាបានការទាំងមូលដដែល។ប៉ុន្តែតុលាការគប្បីពិចារណាលើស្ថានសម្រាលជនជាប់ចោទ៖

+ជនជាប់ចោទឈ្មោះ[redacted] វេន ក្នុងពេលសវនាការឃើញសភាពក្លកនិយាយខ្សាវៗ ពាក់អ៊ុម



Scanned with CamScanner

ច្បាប់ៗ ប្រហាងស្អមស្លាំង ដូចនេះមានការស៊ីសង្វាក់ជាមួយកំណត់ហេតុសុខភាព ចុះថ្ងៃទី១២.០៨.២០២២ របស់ការិយាល័យអប់រំកែប្រែផ្នែកសុខាភិបាលនៃពន្ធនាគារខេត្តព្រះសីហនុ បានបញ្ជាក់ថាសរុបលទ្ធផលនៃការពិនិត្យមានជម្ងឺហឺតរ៉ាំរ៉ៃ និងរលាកសួត ប្រព័ន្ធដង្ហើម២៤ដង/នាទី ប្រព័ន្ធបេះដូង១០២/នាទី ,TA ១៤៣លើ៩៦ ពីលីម៉ែត្របារត ប្រព័ន្ធពោះវៀនការរុករុលចងដង្ហើម។ម្យ៉ាងវិញទៀតតាមការពិនិត្យប្រវត្តិរូបជនជាប់ចោទឃើញថាទើបតែប្រព្រឹត្តបទល្មើសជាលើកទីមួយ ដែលពីមុនមកពុំធ្លាប់ត្រូវបានតុលាការផ្តន្ទាទោសពីបទល្មើសអ្វីឡើយនិងជាមនុស្សមានវ័យចំណាស់មកដល់បច្ចុប្បន្នមានអាយុ៦០ឆ្នាំ។

+ជនជាប់ចោទឈ្មោះ [redacted] សាន់ តាមការពិនិត្យប្រវត្តិរូបឃើញថាទើបតែប្រព្រឹត្តបទល្មើសជាលើកដំបូង ដែលពីមុនមកពុំធ្លាប់ត្រូវបានតុលាការផ្តន្ទាទោសពីបទល្មើសអ្វីឡើយ។ជនជាប់ចោទបានឆ្លើយសារភាពស្មោះត្រង់ ទទួលស្គាល់នូវកំហុសដែលខ្លួនបានប្រព្រឹត្តនិងទទួលខុសត្រូវនូវព្យសនកម្មរបស់ខ្លួនដោយសុខចិត្តសងសំណងទៅឲ្យដើមបណ្តឹង។ជាមនុស្សមានចរិកលក្ខណៈស្លូតបូត សុភាពរាបសារ និងមានវ័យចំណាស់អាយុ៦៣ឆ្នាំ។ជាមនុស្សមានភាពល្ងង់ខ្លៅមិនចេះគិតពិចារណាឲ្យបានវែងឆ្ងាយនូវអំពើនិងផលវិបាកដែលកើតឡើងដោយសារអំពើប្រព្រឹត្តរបស់ខ្លួន។

## ហេតុដូច្នេះសម្រេច

១-ទទួលបណ្តឹងមាស់ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] វេន និងឈ្មោះ [redacted] សាន់ ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខៈ៩៨២/៨២(ញ) ចុះថ្ងៃទី២៨.១២.២០២១ របស់សាលាដំបូងខេត្តព្រះសីហនុ ទុកជាត្រឹមត្រូវតាមច្បាប់ដដែល លើកលែងតែចំណុចទី១ ត្រង់ចំណុច (ក) នៃសេចក្តីសម្រេចត្រូវកែប្រែនិងសម្រេចជាថ្មីដូចខាងក្រោម៖

ត្រូវកែប្រែ ចំណុចទី១.ក លើការផ្តន្ទាទោស៖

ក-ផ្តន្ទាទោសលើឈ្មោះ [redacted] វេន (មានសាវតារជាតិដូចខាងលើ) ពីដាក់ពន្ធនាគារ០២(ពីរ)ឆ្នាំ មកទោសអនុវត្តក្នុងពន្ធនាគារ០២(ពីរ)ខែ ឯទោសដែលនៅសល់ព្យួរធម្មតា តាមមាត្រា៩៣ មាត្រា៩៤ មាត្រា១០៦ និងមាត្រា១០៧ នៃក្រមព្រហ្មទណ្ឌ និងពិន័យជាប្រាក់ចំនួន៤,០០០,០០០(បួនលាន)រៀល។

ខ-ផ្តន្ទាទោសលើឈ្មោះ [redacted] សាន់ (មានសាវតារជាតិដូចខាងលើ) ពីដាក់ពន្ធនាគារ០២(ពីរ)ឆ្នាំ មកទោសអនុវត្តក្នុងពន្ធនាគារ០២(ពីរ)ខែ ឯទោសដែលនៅសល់ព្យួរធម្មតា តាមមាត្រា៩៣ មាត្រា៩៤ មាត្រា១០៦ និងមាត្រា១០៧ នៃក្រមព្រហ្មទណ្ឌ និងពិន័យជាប្រាក់ចំនួន៤,០០០,០០០(បួនលាន)រៀល។

ពីបទៈឆបោក ប្រព្រឹត្តនៅភូមិពូធឿង ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលពីអំឡុងខែមករា ,ខែកុម្ភៈ រហូតដល់អំឡុងខែសីហា ឆ្នាំ២០១៨។បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៣៧៧ និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។

-សាលក្រមនេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វេន និងឈ្មោះ [redacted] សាន់ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] វេន និងឈ្មោះ [redacted] សាន់ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីចាត់ទុកជាចំពោះមុខ។បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមជំនុំជម្រះ**



Scanned with CamScanner